ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៤ លេខ៥១ ត្រីមាសទី០៣ ឆ្នាំ២០២៤

រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន
ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ...

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥០០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ និងសប្បុរសជន ២៨រូប	៦៨៨៣
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥០៨ ស្តីពី ការផ្តល់គោរមងារ ឧកញ៉ា **លឹម សុខលី** ជា អ្នកឧកញ៉ា	៦៨៨៤
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥០៩ ស្តីពី ការផ្តល់គោរមងារ ឧកញ៉ា **ជា ហាច** ជា អ្នកឧកញ៉ា	៦៨៨៥
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១០ ស្តីពី ការផ្តល់គោរមងារ ឧកញ៉ា **គួន ធីតា** ជា អ្នកឧកញ៉ា	៦៨៨៦
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១១ ស្តីពី ការផ្តល់គោរមងារ លោក **ឡាច ម៉ូគៀត** ជា ឧកញ៉ា	៦៨៨៧
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១២ ស្តីពី ការផ្តល់គោរមងារ លោក **ជា សំអាត** ជា ឧកញ៉ា	៦៨៨៨
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៣ ស្តីពី ការផ្តល់គោរមងារ លោក **ហាន់ ជេពខេង** ជា ឧកញ៉ា	៦៨៨៩
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៤ ស្តីពី ការផ្តល់គោរមងារ លោក **សុខ ចំរើន** ជា ឧកញ៉ា	៦៨៩០
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៥ ស្តីពី ការផ្តល់គោរមងារ លោកស្រី **អ៊ិន សុខា** ជា ឧកញ៉ា	៦៨៩១
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៦ ស្តីពី ការផ្តល់គោរមងារ លោក **ស៊ី ទារ៉ុត** ជា ឧកញ៉ា	៦៨៩២
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៧ ស្តីពី ការបញ្ចប់មុខតំណែងពីនាយករងខុទ្ទកាល័យ និងពីទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៩រូប ដោយសាមីខ្លួនសុំលាឈប់	៦៨៩៣
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៨ ស្តីពី ការបញ្ចប់មុខតំណែងពីទីប្រឹក្សា និងពីជំនួយការ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៣រូប ដោយសាមីខ្លួនសុំលាឈប់	៦៨៩៤
២៨-៥-២០២៤	-ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥១៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាជំនួយការ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៥រូប និងតែងតាំងជាជំនួយការ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ២រូប	៦៨៩៥

២៨-៥-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥២០ ស្ដីពី ការតែងតាំង ជាទីប្រឹក្សា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៧រូប ដោយពុំទទួលប្រាក់បំណាច់មុខងារ ៦៨៩៦

២៨-៥-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥២១ ស្ដីពី ការតែងតាំង ជាទីប្រឹក្សា ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ៣រូប ដោយពុំទទួលប្រាក់បំណាច់មុខងារ ៦៨៩៧

២៩-៥-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥២២ ស្ដីពី ការបញ្ចប់មុខតំណែង ឯកឧត្តម **តាន់ មុនីវណ្ណ** ពីទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ រដ្ឋលេខាធិការ ៦៨៩៨

២៩-៥-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥២៣ ស្ដីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ នៅក្រសួងកិច្ចការនារី ដល់មន្ត្រីរាជការ ៧៧ រូប ៦៨៩៩

២៩-៥-២០២៤ -ព្រះរាជក្រឹត្យ នស/រកត/០៥២៤/៥២៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងសប្បុរសជន ៣៦អង្គ/រូប ៦៩០២

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៣-៥-២០២៤ -អនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្ដីពី ការធ្វើអនុប្បយោគប្ដូរចំណាត់ថ្នាក់ទីតាំងដី ០១កន្លែង ទំហំ ១៦ ០៧៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ ដើម្បីដាក់ជួលជូនក្រុមហ៊ុនថ្ងៃបាំងឆ័ត្រ (ខេមបូឌា) ៦៩០៣

៣១-៥-២០២៤ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៦៩០៥

៣១-៥-២០២៤ -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្ដីពី ការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ របស់រាជរដ្ឋាភិបាល ៦៩០៧

៣១-៥-២០២៤ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្ដីពី ការបង្កើតកំពង់ផែពហុបំណងកំពត ៦៩០៩

១៤-៥-២០២៤ -អនុក្រឹត្យលេខ ២៩៣ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៦៩១៤

២៩-៥-២០២៤ -អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្ដីពី ការបញ្ចប់មុខតំណែង និងលុបឈ្មោះមន្ត្រីរាជការ ៦៩១៥

២៩-៥-២០២៤ -អនុក្រឹត្យលេខ ៣២៣ អនក្រ.តត ស្ដីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៩១៦

២៩-៥-២០២៤ -អនុក្រឹត្យលេខ ៣២៤ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ៦៩១៨

៣០-៥-២០២៤ -អនុក្រឹត្យលេខ ៣២៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៦៩២៥

៣០-៥-២០២៤ -អនុក្រឹត្យលេខ ៣២៦ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ៦៩២៦

៣០-៥-២០២៤ -អនុក្រឹត្យលេខ ៣២៧ អនក្រ.តត ស្ដីពី ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ ៦៩២៨

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣២៨ អនក្រ.តត ស្ដីពី ការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ ៦៩៣០

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៣២

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៦៩៣៣

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋាននន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៦៩៣៥

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៦៩៣៧

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ និងឋាននន្តរស័ក្តិមន្ត្រីរាជការ ៦៩៣៩

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៦៩៤៥

៣១-៥-២០២៤ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ និងឋាននន្តរស័ក្តិមន្ត្រីរាជការ ៦៩៤៧

២~សេចក្តីសម្រេច

២៣-៥-២០២៤ -សេចក្តីសម្រេចលេខ ៩៨ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការពិសេស ដើម្បីជំរុញការរៀបចំ និងការអនុវត្តគម្រោងព្រែកជីកហ្វូណនតេជោ ៦៩៨៦

២៩-៥-២០២៤ -សេចក្តីសម្រេចលេខ ១០០ សសរ ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងសិក្សាជំរុញការអភិវឌ្ឍផលិតផលឧស្សាហកម្ម និងចំណីអាហារហាឡាល់នៅកម្ពុជា ដោយប្រើប្រាស់ក្របខ័ណ្ឌតំបន់សេដ្ឋកិច្ចពិសេស ៦៩៩០

៣~សារាចរ

២៣-៥-២០២៤ -សារាចរលេខ ០៧ សរ ស្តីពី ការរៀបចំខួបលើកទី៧៥ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៣ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤ ៦៩៩៣

៤~សារាចរណែនាំ

២១-៥-២០២៤ -សារាចរណែនាំលេខ ០៣ សរណន ស្តីពី ការចូលរួមកាន់ទុក្ខព្រះបរមសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ៦៩៩៦

III~ការងារបណ្តាក្រសួង

១~រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

២១-៥-២០២៤ -ប្រកាសលេខ ០២ រកព.ប្រក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋានរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ៦៩៩៧

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២៧-២-២០២៤ -ប្រកាសលេខ ១០៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីន ហេង យី (ខេមបូឌា) អ៊ិនធើណេសិនណល ត្រេឌីង ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧០១២

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ និងសប្បុរសជន ២៨រូប

ក- គ្រឿងឥស្សរិយយស **ជាតូបការ**

១- ឯកឧត្តម **ចិត្រ សេរីសុវត្ថិ**
២- ឯកឧត្តម **កុសុម សំរេច**
៣- ឯកឧត្តម **ប៉ាន់ ស៊ីអ៊ាន់ថា**
៤- ឯកឧត្តម **ចិត្រ សេរីសុម្រឹត**
៥- ឯកឧត្តម **ញ៉ែម និវា**
៦- លោក **ម៉ននី បណ្ឌិត**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោក **តាំង សម្បត្តិ**

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **គង់ សុវ៉ាត**

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ **ឡាយ ស្រីម៉ាច**
២- លោក **ហ៊ូ ជៀនហៃ**
៣- លោកស្រី **ហ៊័ង យូយហ្វៃ**
៤- លោក **ចាង លីឡាយ**
៥- លោក **ធិន វិចិត្រ**
៦- លោក **សុខ អេង**
៧- លោក **ទឹម វិបុល**
៨- លោក **ប៉ុក លក្ស្មី**
៩- លោក **ស៊ិន សារៈ**
១០- លោកស្រី **ពុធ តារារត្ន័**
១១- លោក **ទេស សាបាន**
១២- លោក **សុខ វល័ក្ខ**
១៣- លោក **ហែម វិមុត្តា**
១៤- លោក **គួ សុភ័ក្រ**
១៥- លោកស្រី **គួ រស្មី**
១៦- លោកស្រី **ណាំ ជីម**

ង គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- លោក **ឈឹម សារ៉ូយ**
២- លោក **ម៉ន ម៉ារឌី**
៣- លោកស្រី **ឆួក លីមឈៀង**
៤- លោក **សួន ជីម**

នរោត្តមសីហមុនី

ពារ. ២៤០៥.៥០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានបង្ហាញត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឧកញ៉ា **លឹម សុខលី**

ជា

អ្នកឧកញ៉ា

នរោត្តមសីហមុនី

ពារល. ២៤០៤.៥១០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឧកញ៉ា **ជា ហាង**

ជា

អ្នកឧកញ៉ា

នរោត្តមសីហមុនី

៣រល.២៤០៥.៥១១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

ឧកញ៉ា **គួន ធីតា**

ជា

អ្នកឧកញ៉ា

នរោត្តមសីហមុនី

៣១៧ល.២៤០៥.៥១២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **ឡាច ប៉ូគៀត**

ជា

ឧកញ៉ា

នរោត្តម សីហមុនី

ពរល.២៤០៥.៥១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **ជា សំអាត**

ជា

ឧកញ៉ា

ពរល.២៤០៥.៥១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **ហាន់ ជេពចន្ទ**

ជា

ឧកញ៉ា

នរោត្តមសីហមុនី

ព្រល.២៤០៥.៥១៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/ ៥១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **សុខ ចំរើន**

ជា

ឧកញ៉ា

នរោត្តមសីហមុនី

ពរល.២៤០៥.៥១៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ត្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោកស្រី **អ៊ិន សុខា**

ជា

ឧកញ៉ា

នរោត្តមសីហមុនី

ព្រះរាជ.២៤០៥.៥១៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **ស៊ី ទារុក**

ជា

ឧកញ៉ា

នរោត្តម សីហមុនី

៣រល.២៤០៥.៥១៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងពីនាយករងខុទ្ទកាល័យ និងពីទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ០៩រូប ដោយសាមីខ្លួនសុំលាឈប់ ៖

១-ឯកឧត្តម **យឹម លាង** ពីនាយករងខុទ្ទកាល័យ និងពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋមន្ត្រី

២-ឯកឧត្តម **ចាន់ សុខុម** ពីនាយករងខុទ្ទកាល័យ និងពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋមន្ត្រី

៣-លោកជំទាវ **សុងឡេង បូរ៉ា** ពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋមន្ត្រី

៤-អ្នកឧកញ៉ា **លី យុនថៃ** ពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋមន្ត្រី

៥-ឯកឧត្តម **ជា យុ៣** ពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ

៦-ឯកឧត្តម **ជាង រ៉េន** ពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ

៧-ឯកឧត្តម **ម៉ម ចាន់ដារ៉ា** ពីទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៨-ឯកឧត្តម **ហេង ច្រាង** ពីទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៩-ឯកឧត្តម **សារុន សារាមុនី** ពីទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣រល.២៤០៥.៥១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឈរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងពីទីប្រឹក្សា និងពីជំនួយការ ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ០៣រូប ដោយសាមីខ្លួនសុំលាឈប់ ៖

១-ឯកឧត្តម **អ៊ាវ ចំរើន** ពីទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម **យឹម សំអាង** ពីទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣-ឯកឧត្តម **ហាក់ ចាន់ភក្តី** ពីជំនួយការ មានឋានៈស្មើ អគ្គនាយក។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ពរល.២៤០៥.៥២០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥ នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ ស្តីពីការជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង និងផ្តល់ឋានៈ ជាជំនួយការ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ៖

១- ឯកឧត្តម ចាន់ វុទ្ធី មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២- ឯកឧត្តម សុខ សំណាង មានឋានៈស្មើ អគ្គនាយក
៣- លោកជំទាវ ម៉ម ពេជ្រសង្វារ មានឋានៈស្មើ អគ្គនាយក
៤- ឯកឧត្តម អ៊ុំ វុទ្ធី មានឋានៈស្មើ អគ្គនាយក
៥- លោកជំទាវ ម៉ម ពេជ្ររស្មី មានឋានៈស្មើ អគ្គនាយក

មាត្រា ២: តែងតាំងជាជំនួយការ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ៖

១- ឯកឧត្តម ហួត វុត្ថា
២- ឯកឧត្តម ញ៉ិល សុវៀត

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល. ២៤០៥.៥២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ០៧រូប ដោយពុំទទួលប្រាក់បំណាច់មុខងារ ៖

១-ឯកឧត្តម **ជាង រ៉េន**
២-ឯកឧត្តម **ម៉ម ចាន់ដារ៉ា**
៣-ឯកឧត្តម **ហេង ច្រេង**
៤-ឯកឧត្តម **សារុន សារាមុនី**
៥-ឯកឧត្តម **ហួរ សុខហេង**
៦-ឯកឧត្តម **សៃ សុឃន**
៧-ឯកឧត្តម **ភិន សុភារក្ស**

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នរោត្តមសីហមុនី

៣រល. ២៤០៥.៥២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានយកសេចក្តីគោរពតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា នាសម័យប្រជុំលើកដំបូងព្រឹទ្ធសភា នីតិកាលទី៥ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សាឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ០៣រូប ដោយពុំទទួលប្រាក់បំណាច់មុខងារ ៖

១-ឯកឧត្តម **រឹម ចំរើន**

២-ឯកឧត្តម **ហាក់ ចាន់តត្ថី**

៣-ឯកឧត្តម **យឹម សំអាង**

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរល. ២៤០៥.៥២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

នស/រកត/០៥២៤/៥២២

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/២០៧១ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងផ្តល់ឋានៈជាទីប្រឹក្សា និងជំនួយការក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែង ឯកឧត្តម **តាន់ មុនីវណ្ណា** ពីទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើរដ្ឋលេខាធិការ។

មាត្រា២ : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរល.២៤០៥.៥២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកិច្ចការនារី ដល់មន្ត្រីរាជការ **៧៧** រូប ចាប់ពីថ្ងៃទី**១៣** ខែ**មេសា** ឆ្នាំ**២០២៤** ៖

១-លោកស្រី **អ៊ុក ណារី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២-លោកស្រី **ឪ រ៉ានី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣-លោក **ស៊ឹ វណ្ណសាន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤-លោកស្រី **តែ ខួចលីម**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៥-លោកស្រី **សុខ សុធាវី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៦-លោកជំទាវ **ម៉ុនឈិត វាសនា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧-លោកជំទាវ **ជា ហ៊ើង**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨-លោកស្រី **ចាន់ សាម៉ីឌី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩-លោក **យិន កន្និកា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០-លោកស្រី **សន សុខា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១១-លោកស្រី **ទុំ សារានី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១២-ឯកឧត្តម **ថេ ឈុនហាក់**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣-លោកស្រី **ថន គាពផានីតា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១៤-លោក **ជីន ចន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥-លោកស្រី **អ៊ុក ណារ៉ូ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៦-លោកស្រី **អ៊ុក សុខមុនី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៧-លោកស្រី **ឃឹម តារី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៨-លោកស្រី **ម៉េង គីមហួយ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៩-លោក **ទៀង មុនី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២០-លោកស្រី **ឆូ គីមសិត**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
២១-លោកស្រី **និត ស្រីយ៉ា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២២-លោកស្រី **ចិន អមរា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៣-លោកស្រី **រស់ តីណា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៤-លោក **ទឹម តីយ៉ារី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៥-លោកស្រី **ដើក ហាន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៦-ឯកឧត្តម **សៅ ខត្យវីរៈ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៧-លោក **ម៉ែន សម្បត្តិ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៨-លោកស្រី **ទូច ស្រីដេត**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
២៩-លោកស្រី **ថន សសិកា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
៣០-លោក **ហ៊ី សុផាន្នី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
៣១-លោក **យស់ ម៉ាច**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
៣២-លោកស្រី **នូ បុប្ផា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	មកជាថ្នាក់លេខ ៤
៣៣-លោកជំទាវ **ថងតៀន ឆ័យម៉ាលី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៤-លោកស្រី **សាខ គីមសឿន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៥-លោកស្រី **មៀច សុធ្ធារី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៦-លោកស្រី **គូ សុធ្ធា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៧-លោកស្រី **ស ស៊ីណែត**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៨-លោក **តែ ស៊ីថន**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៣៩-លោកស្រី **ឡេង មោនីផា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤០-លោកស្រី **ហួត រី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤១-លោកស្រី **យួម យ៉ា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤២-លោកស្រី **ឈឹម សោភ័ណ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤៣-លោក **ប៊ិន សម្បត្តិ**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤៤-លោកស្រី **ម៉ន រតនា**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤៥-លោកស្រី **នង ម៉ារី**	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	មកជាថ្នាក់លេខ ៥
៤៦-លោកស្រី **សេងផល ដាវីន**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៧-លោកស្រី **ឡេង មោនីភាព**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៨-លោក **ចៀម គីមហួ**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤៩-លោកស្រី **សួង ម៉ារ៉ាដា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥០-លោកស្រី **ហ៊ួ សុផល្លីកា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥១-លោកស្រី **ធឿន សមនា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦

៥២-លោកស្រី **តែ ទេវី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៣-លោក **សុខ ឆេង**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៤-លោកស្រី **គី ណារ៉ែន**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៥-លោកស្រី **អាយ សោភា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៦-លោកស្រី **ប៉ោក សារ៉ែន**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៧-លោក **ញ៉ឹម លក្ខិណា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៨-លោកស្រី **សៅ សុភ៉ានី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៥៩-លោក **ស៊ឹម សុផារិទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦០-លោកស្រី **មន ណាវី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦១-លោក **ផាន់ណា រ៉េមី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦២-លោកស្រី **ឯក ច័ន្ទនីវ៉ាដា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៣-លោកស្រី **ឃឿង ចាន់ឌី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៤-លោកស្រី **ឌុល សុខុម**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៥-លោកស្រី **ប៉ែន សំអុល**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៦-លោកស្រី **សាយ សុភា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៧-លោកស្រី **សូ ប៊ុណ្ណារី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៨-លោកស្រី **អេត អញ្ញា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៦៩-លោកស្រី **យ៉ាន់ ម៉ូនីកា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧០-លោកស្រី **ភាន់ រតនឧប្បល**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧១-លោកស្រី **គ្រាន់ ស៊ីថាវី**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧២-លោកស្រី **សៅ ភាន**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧៣-លោកស្រី **ធី ផល្លីដា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧៤-លោកស្រី **ឃិន សាវ៉ាត**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧៥-លោក **សោម ច័ន្ទតារ៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧៦-លោកស្រី **ព្រាប ផល្លា**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦
៧៧-លោកស្រី **ប៊ីន សុភ័ស្ត**	ពីវរមន្ត្រី ថ្នាក់លេខ ១	មកជាឧត្តមមន្ត្រី ថ្នាក់លេខ ៦

មាត្រា ២ :សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

ពរស. ២៤០៥.៥២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ថៃ ចរិយា? — ថៃ ចិស្សុត?

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៥២៤/៥២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី**
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងដល់សប្បុរសជន ៣៦អង្គ/រូប៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

១- ព្រះយសវរធម្ម	ដួង សុចិត្ត	២- អ្នកឧកញ៉ា	សំអាង វឌ្ឍនៈ
៣- លោកជំទាវ	ឡៅ គីមណៃ	៤- ឧបាសក	កុយ ទីង
៥- ឧបាសិកា	ខេន សារុន	៦- ឧបាសិកា	អ៊ាង សុផាត
៧- ឧបាសិកា	សុខ សុខុម	៨- ឧបាសិកា	ខេង ច័ន្ទគ្រីស្នា
៩- លោកជំទាវ	ឃុន ធានី	១០- ឯកឧត្តម	សារ៉ី ផល្លា

ខ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- ព្រះអង្គ	ផុនផៃ ពីនយ៉ាផង់	២- លោកជំទាវ	ឈរ ណារី
៣- លោកជំទាវ	ឆាយ ស៊ីណា	៤- លោកជំទាវ	ជុំ សាមីន
៥- លោកជំទាវ	ទេព វង្សី	៦- លោកជំទាវ	សន ម៉ារ៉ាដា
៧- លោកជំទាវ	យិន ផាន្នី	៨- លោកជំទាវ	គាត កុលណី
៩- លោកជំទាវ	ស៊ុន សុម៉ាលី	១០- លោក	គឹម ស៊ីរ៉ា
១១- ឧបាសិកា	សុខ ថាច	១២- ឧបាសិកា	អឿន សំបូរ
១៣- ឧបាសិកា	ផុន ស៊ីមហ៊ាង	១៤- ឧបាសិកា	ព្រំ ធារី

គ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានីព្រះស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរ័ត្ន** ថ្នាក់ **មហាសេនា**

១- ឧបាសិកា	ជរ ប៊ុណ្ណារី	២- ឧបាសិកា	អៀ អ៊ុយ
៣- ឧបាសិកា	ដួង សុខេន	៤- ឧបាសក	អុន ផល
៥- ឧបាសក	អៀង សុភាព	៦- លោក	អ៊ា តាល់
៧- លោក	ចឹក ស៊ីនឿន	៨- លោកស្រី	ឈឹម សិទ្ធីធីតា
៩- លោក	ស្វាយ ហ៊ីន	១០- លោក	ជួប ជឿន
១១- លោក	នឹម ហន	១២- លោក	សុខ ចំរើន

ពរល: ២៤០៥.៥២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២៤

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៤ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការធ្វើអនុប្បយោគប្ដូរចំណាត់ថ្នាក់ទីតាំងដី ០១កន្លែង ទំហំ ១៦ ០៧៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ ដើម្បីដាក់ជួលជូនក្រុមហ៊ុនថ្ងៃបាំងធំត្រ (ខេមបូឌា)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១.-

ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងលើផ្ទៃដីទំហំ ១៦ ០៧៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប សម្រាប់ផ្តល់ជូនក្រុមហ៊ុនថ្ងៃបាំងឆ័ត្រ (ខេមបូឌា) ដើម្បីបន្តនីតិវិធីរៀបចំបំពេញបែបបទនីតិវិធីជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា២.-

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋលើផ្ទៃដីទំហំ ១៦ ០៧៣ ម៉ែត្រក្រឡា ដូចមានចែងក្នុងប្រការ១ នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុនថ្ងៃបាំងឆ័ត្រ (ខេមបូឌា) លើគម្រោងវិនិយោគអភិវឌ្ឍសេវាទេសចរណ៍ក្នុងតំបន់រុក្ខជាតិបៃតង និងតំបន់ជាប់មាត់សមុទ្រ ដែលត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តកែប ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

<u>សម្រេច</u>

មាត្រា១ .-

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាចំនួន ២ ០០០ ០០០ ០០០ រៀល (ពីរប៊ីលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) មកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤។

មាត្រា២ .–

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជួសជុលការលិចទឹកដំបូលអគារ និងការជ្រាបទឹកនៅតាមជាន់នៃទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងឆ្នាំ ២០២៤។

មាត្រា៣ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៣ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ របស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្ដីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈរបស់រាជរដ្ឋាភិបាល បើកផ្តល់ថវិកាចំនួន **៧៥ ៧៩៣ ដុល្លារអាម៉េរិក** (ចិតសិបប្រាំពាន់ ប្រាំពីររយកៅសិបបីដុល្លារអាម៉េរិក) ដើម្បីលើកទឹកចិត្តដល់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមការងារអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដែលបានខិតខំប្រឹងប្រែងកៀរគរចំណូលពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈរបស់ក្រសួង ស្ថាប័ន និងមន្ទីរ-អង្គភាពពាក់ព័ន្ធ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៩ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតកំពង់ផែពហុបំណងកំពត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៤/០០២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសន្តិសុខនាវានិងសន្តិសុខបបនីយកណ្ឌផែ
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ស្តីពីការធ្វើអនុបយោគដីបូមចំនួន១ ០០០ហិកតា ស្ថិតនៅភូមិគីឡូ១២ ឃុំកោះតូច និងឃុំបឹងឈូក ស្រុកកំពត ខេត្តកំពត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើត **កំពង់ផែពហុបំណងកំពត** ដែលមានទីតាំងស្ថិតនៅសង្កាត់កោះតូចនិងសង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត ដើម្បីបម្រើសេវាឱ្យនាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ចូលចេញ ផ្ទេរផ្ទុក លើកដាក់ និងរក្សាទុកទំនិញជាកុងតឺន័រ ទំនិញទូទៅ និងអ្នកដំណើរ។

៤៨

ជំពូកទី២
ការកំណត់ដែនកំពង់ផែ

មាត្រា២ .-

កំពង់ផែពហុបំណងកំពត មានដែនទឹកនិងដីគោក។

ដែនទឹកមានទំហំ៦៧៨(ប្រាំមួយរយចិតសិបប្រាំបី)ហិកតា និងដីគោកមានទំហំ២០៧(ពីររយប្រាំពីរ) ហិកតា ដែលមានព្រំដែននិងនិយាមកានៅក្នុងប្លង់រួមនិងព្រំដែនកំពង់ផែពហុបំណងកំពត ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា៣ .-

ដែនទឹកនៃកំពង់ផែពហុបំណងកំពត ដូចមានចែងនៅក្នុងកថាខណ្ឌទី២ មាត្រា២ ខាងលើនេះ ត្រូវទុកជាកម្មវត្ថុសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ដោយអង្គគ្រប់គ្រងកំពង់ផែពហុបំណងកំពត ដែលរួមមានប្រឡាយនាវាចរណ៍ សញ្ញាជំនួយនាវាចរណ៍ អាងបត់ និងបបនីយកណ្ឌផ្សេងទៀត ដែលធានាដល់ការថែរក្សាការពារសុវត្ថិភាព សន្តិសុខ និងបរិស្ថាននៅក្នុងដែនទឹកនៃកំពង់ផែនេះ។

ជំពូកទី៣
ឋបនីយកណ្ឌផែ

មាត្រា៤ .-

កំពង់ផែពហុបំណងកំពត មានឋបនីយកណ្ឌផែទំនិញ ដែលមានសមត្ថភាព៨០០ ០០០TEU (ប្រាំបីរយពាន់ធីអ៊ីយូ) និងឋបនីយកណ្ឌផែអ្នកដំណើរ។

ឋបនីយកណ្ឌផែទំនិញ មានជាអាទិ៍ទីលានកុងតឺន័រ ទីលានទំនិញទូទៅ ឃ្លាំងស្តុកទំនិញ អគារត្រួតពិនិត្យទំនិញ រោងម៉ាស៊ីនភ្លើង បន្ទប់ទឹក និងមានបំពាក់គ្រឿងចក្រនិងឧបករណ៍គ្រប់គ្រាន់ស្របតាមសមត្ថភាពរបស់ឋបនីយកណ្ឌផែនីមួយៗ។

ឋបនីយកណ្ឌផែអ្នកដំណើរ មានជាអាទិ៍អគារអ្នកដំណើររង់ចាំ ចំណតរថយន្តសម្រាប់អ្នកដំណើរឡើងចុះ និងឋបនីយកណ្ឌផ្សេងៗទៀតដែលចាំបាច់។

មាត្រា៥ .-

កំពង់ផែពហុបំណងកំពត មានប្រឡាយនាវាចរណ៍ ដែលមានបណ្តោយប្រវែង២ ៦០០(ពីរពាន់ប្រាំមួយរយ)ម៉ែត្រ ទទឹងប្រវែង៣០០(បីរយ)ម៉ែត្រ ជម្រៅទឹកកម្ពស់១៣(ដប់បី)ម៉ែត្រ និងមានអាងបត់ដែលមានអង្កត់ផ្ចិត១ ០០០(មួយពាន់)ម៉ែត្រ។

មាត្រា៦ .-

កំពង់ផែពហុបំណងកំពត អាចប្រើតំបន់រង់ចាំឬតំបន់សម្រាលទំនិញ ដែលស្ថិតនៅក្រៅដែនទឹកនៃកំពង់ផែ ហើយដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

មាត្រា៧ .-

ឋបនីយកណ្ឌផែនៃកំពង់ផែពហុបំណងកំពត មានរបងព័ទ្ធជុំវិញនៅផ្នែកដីគោក ច្រកចូលចេញនិងបំពាក់នូវប្រព័ន្ធអេឡិចត្រូនិកទំនើប ដើម្បីធានាដល់ប្រតិបត្តិការកំពង់ផែនិងវិធានការសន្តិសុខនិងសុវត្ថិភាពនៃកំពង់ផែទាំងមូល។

មាត្រា៨ .-

កំពង់ផែពហុបំណងកំពត មានអគាររដ្ឋបាលមួយកន្លែង ដែលរួមមានទាំងការិយាល័យធ្វើការរបស់មន្ត្រីចត្តាឡីស័ក មន្ត្រីនគរបាលអន្តោប្រវេសន៍ មន្ត្រីគយនិងរដ្ឋាករកម្ពុជា និងមេបញ្ជាការផែ។

ជំពូកទី៤
អង្គគ្រប់គ្រងកំពង់ផែពហុបំណងកំពត

មាត្រា៩ .-

ក្រុមហ៊ុនកំពត ផត ជាអង្គគ្រប់គ្រងកំពង់ផែពហុបំណងកំពត។

មាត្រា១០ .-

ក្រៅពីកាតព្វកិច្ចឬភារកិច្ចរបស់ខ្លួនក្នុងធុរកិច្ចផ្តល់សេវាដល់នាវាដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ អង្គគ្រប់គ្រងកំពង់ផែពហុបំណងកំពត ត្រូវបំពេញភារកិច្ច ដែលមានជាអាទិ៍៖

- រៀបចំផែនការអភិវឌ្ឍន៍កំពង់ផែពហុបំណងកំពត ការសាងសង់ និង/ឬជួសជុលកំពង់ផែពហុបំណងកំពត
- រៀបចំកន្លែងធ្វើការសម្រាប់មន្ត្រីមានសមត្ថកិច្ច រួមមានមន្ត្រីចត្តាឡីស័ក មន្ត្រីនគរបាលអន្តោប្រវេសន៍ មន្ត្រីគយនិងរដ្ឋាករកម្ពុជា និងមេបញ្ជាការផែ
- បួមស្តារ ថែទាំ គ្រប់គ្រង ការពារ និងប្រើប្រាស់ប្រឡាយនាវាចរណ៍ រួមទាំងការបំពាក់សញ្ញាជំនួយនាវាចរណ៍និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ដើម្បីធានាឱ្យមានសុវត្ថិភាព សន្តិសុខ និងបរិស្ថានសម្រាប់នាវាចរណ៍ដែលស្ថិតនៅក្នុងដែនទឹកនៃកំពង់ផែពហុបំណងកំពត
- រៀបចំតារាងថ្លៃឈ្នួលកំពង់ផែពហុបំណងកំពតនិងអនុវត្តការប្រមូលថ្លៃសេវាស្របតាមតារាងថ្លៃឈ្នួលនោះ
- រៀបចំនិងផ្តល់របាយការណ៍អំពីប្រតិបត្តិការឋបនីយកណ្ឌផែនៃកំពង់ផែពហុបំណងកំពត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើទំនើបកម្មកំពង់ផែពហុបំណងកំពត ស្របតាមតម្រូវការចាំបាច់ ដូចមានចែងនៅក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជំពូកទី៥
មន្ត្រីមានសមត្ថកិច្ចប្រចាំការនៅកំពង់ផែពហុបំណងកំពត

មាត្រា១១ .-

កំពង់ផែពហុបំណងកំពត ត្រូវមានមន្ត្រីមានសមត្ថកិច្ចប្រចាំការ ដែលរួមមានមន្ត្រីចត្តាឡីស័កនៃក្រសួងសុខាភិបាល មន្ត្រីនគរបាលអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ មន្ត្រីគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមេបញ្ជាការផែនៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីអនុវត្តច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ជំពូកទី៦
ការផ្ទេរកម្មសិទ្ធិ

មាត្រា១២ .-

ក្នុងករណីដែលមានការលក់ទិញ ការដូរ ប្រទានកម្ម ឬមូលហេតុគតិយុត្តផ្សេងទៀតដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិផ្នែកណាមួយឬទាំងមូលនៃកំពង់ផែពហុបំណងកំពត ឬការផ្ទេរភាគហ៊ុន ក្រុមហ៊ុនកំពត ផត ត្រូវជូនដំណឹងទៅក្រសួងសាធារណការនិងដឹកជញ្ជូន យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការផ្ទេរកម្មសិទ្ធិកំពង់ផែពហុបំណងកំពតឬការផ្ទេរភាគហ៊ុននៃក្រុមហ៊ុនកំពត ផត។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា១៣ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៤ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប៉េង ពោធិ៍នា

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤

ស្តីពីការបង្កើតកំពង់ផែពហុបំណងកំពត

ប្លង់រួមនិងព្រំដែនកំពង់ផែពហុបំណងកំពត



១

[illegible]		
PROJECTION UTM ZONE 48N. DATUM WGS 84		
A	399940.434	1163757.449
B	402703.972	1163757.023
C	402704.191	1162978.807
D	400035.925	1162989.830
E	400035.396	1163570.256

២

[illegible]		
PROJECTION UTM ZONE 48N. DATUM WGS 84		
1	399534.171	1161291.783
2	399535.926	1161291.783
3	400760.180	1161286.450
4	400661.871	1160387.783
5	401667.837	1160387.783
6	401765.668	1161282.069
7	403204.195	1161275.802
8	403204.097	1163318.241
9	402704.295	1163318.241
10	402704.191	1162978.807
11	400035.925	1162989.830
12	400035.396	1163570.256
13	399940.434	1163757.449

118

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៩៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូន Dr.Ginevra Boatto អ្នកជំនាញការ និងជាតំណាងអង្គការមូលនិធិប្រាសាទពិភពលោក(WMF)ប្រចាំអាស៊ីអាគ្នេយ៍ ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរាលើគម្រោងការដ្ឋានជួសជុលប្រាសាទព្រះខ័ន ប្រាសាទតាសោម និងរោងទងកូរសមុទ្រទឹកដោះនៃប្រាសាទអង្គរវត្តកន្លងមក។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការបញ្ចប់មុខតំណែង និងលុបឈ្មោះមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ NS/ KRT-34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៥៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង និងព្រះរាជក្រឹត្យនស/រកត/០៣០៧/១០៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៧ ត្រាស់បង្គាប់បង្កើតនាយកដ្ឋានបុគ្គលិក និងធនធានមនុស្ស នៃក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រឹត្យនស/រកត/០៨០៤/១៦៥ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៤ ស្តីពីការតែងតាំងសម្តេចចៅហ្វាវាំង វររៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- យោងអនុក្រឹត្យលេខ៨៧៦ អនក្រ.តត ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់ចំពោះមុខ ។

សម្រេច

មាត្រា១ : បញ្ចប់មុខតំណែងលោក ស៊ុង ប៊ុនថាន ឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ១ ពីជំនួយការក្រសួងព្រះបរមរាជវាំង ឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា២ : លុបឈ្មោះលោក ស៊ុង ប៊ុនថាន ចេញពីក្របខណ្ឌរដ្ឋនៅក្រសួងព្រះបរមរាជវាំង ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ[illegible] ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៣៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ផ្ទេរ និងតែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ចំនួន **០២រូប** នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖

១-លោកឧត្តមសេនីយ៍ទោ **ផាន់ សុផល** អត្តលេខ ០៧៨៤ ពីប្រធាននាយកដ្ឋានវិទ្យុទាក់ទង ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌

២-លោកឧត្តមសេនីយ៍ទោ **ចេង ហុង** អត្តលេខ ៩០៨៨៨ ពីអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ទៅជាប្រធាននាយកដ្ឋានវិទ្យុទាក់ទង ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ៧ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

អន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ដំឡើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ដល់មន្ត្រីរាជការចំនួន **២១៤ រូប** ចាប់ពីថ្ងៃទី**១៣ ខែមេសា ឆ្នាំ២០២៤** ដូចមាននាយនាមខាងក្រោម ៖

១-ឯកឧត្តម **ឆិត សុធា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២-ឯកឧត្តម **មាស ទិបុល**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១

៣-ឯកឧត្តម **គឹម សុវណ្ណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤-លោក **អូម ចាន់ភក្តី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៥-ឯកឧត្តម **ឆាំង ហ៊ុយ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៦-ឯកឧត្តម **ចាន់ ពិសិដ្ឋ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៧-ឯកឧត្តម **ស្រ៊ាង ចិន្តា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៨-ឯកឧត្តម **ម៉ា នរិទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៩-លោក **ពៅ ចាន់បូផល**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១០-លោកស្រី **លឹម កិត្យា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១១-លោក **ណើ វណ្ណារិទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១២-លោក **ឡៀង អរុណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៣-លោកស្រី **ហ៊ុយ ច័ន្ទសោភា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៤-លោក **ណែត ម៉ុនឃាង**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៥-លោក **អ៊ុត សំអ៊ាត**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៦-លោក **គង់ វីរៈ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៧-លោកស្រី **ជា សុមាលីណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៨-លោកស្រី **ឆៀម កល្យាណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
១៩-លោក **ឌិន សុសម្ផស្ស**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២០-លោក **ញ៉ែម ឆុល**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២១-លោក **ហៃ សុខាណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២២-លោក **ជា វិច្ឆិកា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៣-លោកស្រី **មាស ផល្លា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៤-លោក **ខួន ណារិទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៥-លោក **ញ៉ែត ចាន់**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៦-លោកស្រី **ឌិន សាវី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៧-លោក **អ៊ឹម សុភ័ណា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៨-លោក **សម្បត្តិ សុបញ្ញា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
២៩-លោក **សោ ទេពសុបុត្ត**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣០-លោក **យិន ច័ន្ទធីរ៉ាវុធ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣១-លោក **អ៊ឹម ចាន់វណ្ណស្លុង**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣២-លោក **តុំ ណារីម**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៣-លោក **ហូ វឌ្យវឌ្ឍនៈ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៤-លោក **ច្រឹង វណ្ណី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៥-លោកស្រី **ឆឹយ ម៉ាលី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៦-លោក **សឿន សម្បត្តិ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៧-លោកស្រី **កិច ចាន់សុធី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៨-លោក **ព្រាប រដ្ឋា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៣៩-លោក **ឈន ម៉ុនឆាយ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤០-លោក **ហោង សុភី**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១

៤១-លោក **ម៉ន ឧត្តា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤២-លោក **ឱត ស៊ីដេត**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤៣-លោក **ខង ប៊ុនធឿន**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤៤-លោកស្រី **គេត សុគន្ធា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤៥-លោក **ជា ធារិទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤៦-លោក **ជ័យ តេនា**	ពីវរមន្ត្រី ថ្នាក់លេខ ២	មកជាថ្នាក់លេខ ១
៤៧-លោកជំទាវ **ឈី វិជ្ជ៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៨-ឯកឧត្តម **មាស មូរ៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៤៩-ឯកឧត្តម **ម៉ៅ វិបុល**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥០-ឯកឧត្តម **ស្មើ ឧត្តម**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥១-ឯកឧត្តម **ហាក់ សុខហេង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥២-ឯកឧត្តម **ប្រាក់ គីមហុង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៣-ឯកឧត្តម **សៀក វិចិត្រ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៤-ឯកឧត្តម **ទូស្លា សត្យា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៥-ឯកឧត្តម **ហង់ ផល្លា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៦-លោកស្រី **សុវណ្ណារ៉ា ប៉ារ៉ូនី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៧-ឯកឧត្តម **សេដ្ឋា វឌ្ឍនា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៨-ឯកឧត្តម **ជួង សុផល**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៥៩-ឯកឧត្តម **ម៉ៅ ប៊ុនញ្ញាត្ត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦០-លោក **ជឹម ច័ន្ទស៊ីដេត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦១-លោក **ហ៊ាន គឹមស៊ីន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦២-លោក **គ្រឹម សត្យា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៣-លោក **ចៅ សិទ្ធិគុណា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៤-លោក **ចាន់ វណ្ណី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៥-លោកស្រី **ម៉ី តាវី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៦-លោក **សែម សម**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៧-លោក **ជា មុនីរ័ត្ន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៨-លោក **ណាំ ហេងស៊ីណាន់**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៦៩-លោក **យា សារឿន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧០-លោក **នី ញ៉ូ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧១-លោក **អែម សំណាង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧២-លោក **ឆេង ហ៊ាង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៣-លោក **ចាន់ ឌីម៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៤-លោក **ជឹម ធឿន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៥-លោក **ហេង ស៊ីនេន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៦-លោក **ឈុន ឆាយា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៧-លោក **សេង សុផាត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៧៨-លោក **ម៉ៅ សុផាន់ណារ៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២

៧៩-លោក **ធឿន វណ្ណៈ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨០-លោក **យោង ចាន់អេណា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨១-លោក **អៀម សុភ័ណ្ឌ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨២-លោក **វិសិដ្ឋ សុវត្ថិ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៣-លោក **អ៊ុយ សែន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៤-លោក **នាង សុជាតិ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៥-លោក **រ៉េត ជូឡុង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៦-លោក **សេង ដារ៉ាវុធ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៧-ឯកឧត្តម **ស្វាយ ដូត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៨-លោក **ហុង ចាន់ដា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៨៩-លោក **មៀច គន្ធាមុន្នី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩០-លោក **ជុំ ជឿត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩១-លោក **ហេង សុខណា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩២-លោក **សំរិទ្ធ សុជាតិ**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៣-លោក **ស្រេង ហ៊ុន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៤-លោក **អែម ម៉ាឌី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៥-លោក **ខឹម ផល្លា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៦-លោកស្រី **អ៊ុក គន្ធី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៧-លោក **សួន មិថុនា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៨-លោកស្រី **វ៉ាន់ សម្ផស្ស**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
៩៩-លោក **លី ហ្សះរី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០០-លោកស្រី **ពៅនី សុខនាង**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០១-លោក **សន សាវ៉េត**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០២-លោក **ស្វាយ ចាន់មុនី**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០៣-លោកស្រី **សំរិទ្ធិ ចរិយា**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០៤-លោក **នេត ចំរើន**	ពីវរមន្ត្រី ថ្នាក់លេខ ៣	មកជាថ្នាក់លេខ ២
១០៥-ឯកឧត្តម **ឆេង ស៊ីថា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១០៦-ឯកឧត្តម **មល់ រឿងសីហា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១០៧-ឯកឧត្តម **យ៉ិច ជាវឡេង**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១០៨-ឯកឧត្តម **ខត្យ វ៉ាន់នី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១០៩-លោកស្រី **ឈួន រតនា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១០-លោក **នង ចាន់ថុល**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១១-លោកស្រី **សម ពេជ្របញ្ញា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១២-លោកស្រី **ប៉ែន ច័ន្ទដាវី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៣-លោក **ហាម ម៉ង់ហេង**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៤-លោក **ធិន ភិរុណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៥-លោក **សាយ ភីរុណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៦-លោក **ហេង ប៊ុនឡាយ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

១១៧-លោកស្រី **ឌុច លក្ខិណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៨-លោក **មោង វាសនា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១១៩-លោក **ហ៊ាច ដេត**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២០-លោកស្រី **គេនធី វីរៈយុទ្ធ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២១-លោក **វ៉ាន់ថន ឋានរ៉ា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២២-លោក **ថៃ ពិភក្តិ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៣-លោក **ហួន ស៊ីន**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៤-លោក **ផៃ សុភាព**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៥-លោក **អាំង ហ៊ីត**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៦-លោក **ហង្ស វីរៈភាព**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៧-លោក **ហាក់ ស៊ីណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៨-លោកស្រី **ស៊ន់ សុភាព**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១២៩-លោក **រស់ សាវី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣០-លោក **ហ៊ុន សុភក្តិ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣១-លោកស្រី **គេត ផាន់ណារី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣២-លោក **យ៉េង យាប**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៣-លោក **ថោង វិមាន**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៤-លោក **ម៉ារ៉ា ដួណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៥-លោក **ស៊ាន វណ្ណានី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៦-លោកស្រី **គង់ មុនិតា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៧-លោកស្រី **ប៉ោក លក្ខិណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៨-លោក **ឆាយ ពិសិដ្ឋ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៣៩-លោក **លី កុម្ភៈ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤០-លោក **មូ សារ៉ាវង្ស**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤១-លោក **ពៅ សាវុធ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤២-លោក **ថុន ថៃ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៣-លោក **មុត ខ្វាន់សំរោតវាសនា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៤-លោក **តី សុភា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៥-លោកស្រី **មូល ស្រីវណ្ណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៦-លោកស្រី **ជា ផល្លីន**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៧-លោក **លី ហ្សុះរី**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៨-លោក **រ៉ា វ៉ាន់ថា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៤៩-លោក **ឡាយ ប៊ុនថា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥០-លោក **ជួន ជីវិត**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥១-លោក **ស្វាយ ពិសិដ្ឋ**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥២-លោក **ឌួង សុខហេង**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥៣-លោក **ធី ស៊ីណា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣
១៥៤-លោក **ស្រី សីហា**	ពីវរមន្ត្រី ថ្នាក់លេខ ៤	មកជាថ្នាក់លេខ ៣

១៥៥-ឯកឧត្តម **គួច ខែងស្រ៊ុន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៥៦-ឯកឧត្តម **លី អ៊ិមឡាក់**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៥៧-ឯកឧត្តម **មុំ ទិសុទ្ធដ្ឋារ៉ូ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៥៨-ឯកឧត្តម **សេង ម៉ានោឫទ្ធិ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៥៩-លោកជំទាវ **មួង សកុណា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦០-ឯកឧត្តម **មុំ សាមិត្តរីហ្លួន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦១-លោកជំទាវ **ឆួន សុណោតា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦២-លោកស្រី **សាយ សារ៉ាមី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៣-លោក **សុខ សុផល**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៤-លោក **ហ៊ីត សេងហោ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៥-លោក **នេត បញ្ញា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៦-លោកស្រី **ម៉ែន ចរិយា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៧-លោកស្រី **ឆេង សុគន្ធី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៨-លោកស្រី **ម៉ុន ស៊ីណា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៦៩-លោកស្រី **ថាន់ ដារីទារី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧០-លោក **ឡុង សុខលេង**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧១-លោកស្រី **សួន ស៊ីណុន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧២-លោក **ឡាច វាសនា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៣-លោក **សឿង ណារិទ្ធ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៤-លោក **រៀល ប្រសិទ្ធ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៥-លោក **ខៀវ ចាន់វិចិត្រ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៦-លោក **ផ្លុង ពន្លឺរ័តន៍**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៧-លោក **គឹម រិទ្ធី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៨-លោក **ថៃ សម្បត្តិ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៧៩-លោក **ណែត សីហា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨០-លោក **ភាំង ដារ៉ា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨១-លោក **បូរ តិរុណា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨២-លោក **ចាន់ រិទ្ធី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៣-លោក **ហេង សុជាតិ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៤-លោក **ស៊ិន រ័ត្ន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៥-លោក **ឃួយ កុសល**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៦-លោក **គួយ ស្តុះស្តែន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៧-លោក **ឌិន តារះ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៨-លោក **លឿង គីមឡេង**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៨៩-លោកស្រី **នៃល កល្យាណា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩០-លោក **ច័ន្ទ សុភក្តី**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩១-លោក **ឃុន ចំណាន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩២-លោក **ឆូ តារម្យ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៩៣-លោក **អ៊ីម ទុត្ថា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៤-លោកស្រី **ឡុង ដាលីន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៥-លោកស្រី **ទូន ច័ន្ទសេរីរ័ត្ន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៦-លោក **នុត ផល្លឹម**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៧-លោក **សៅ សារិន្រ្ទ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៨-លោកស្រី **ហ៊ាង សួគ៌ា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
១៩៩-លោកស្រី **រ៉ុម សោភ័ណ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០០-លោកស្រី **សួន ស៊ីណែត**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០១-លោក **ប៉ែន មិថុនា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០២-លោក **ម៉ី ឧឡ្សនៈ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៣-លោក **ជុំ សៅរ៍សោវ៉ាត់**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៤-លោក **មាស ឧឡ្សនៈ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៥-លោកស្រី **ហែម អ៊ុំសិទ្ធិដានិច**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៦-លោក **យិន ច័ន្ទវាសនា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៧-លោក **ទេព វន្ថា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៨-លោក **គី វាសនា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២០៩-លោក **ដាញ់ សារឿន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២១០-លោក **សោម ជុំរ៉ុង**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២១១-លោក **មឿង ចំរើន**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២១២-លោក **លឹម សុវណ្ណារិទ្ធ**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២១៣-លោក **ឈឿន ម៉ុនឆា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤
២១៤-លោក **ពៅ សេតារា**	ពីអនុមន្ត្រី ថ្នាក់លេខ ១	មកជាវរមន្ត្រី ថ្នាក់លេខ ៤

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៧ រោច ខែពិសាខ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៥ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការតែងតាំងមន្ត្រីរាជការ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងបើកផ្ដល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា១ : តែងតាំងជាសមាជិកក្រុមលេខាសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២រូប ដូចមាននាមខាងក្រោម៖

១- លោក **ពេជ្រ មេសា**

២- លោក **ឆាង ពេជ្រវិជ្ជា**

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.កត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១ .- ដាក់មន្ត្រីរាជការចំនួន ០២ រូប របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល ០១(មួយ)ឆ្នាំ តាមការស្នើសុំរបស់សាមីខ្លួន ដូចមានរាយនាមខាងក្រោម៖

១- លោក **ហុង សុគន្ធ**	មុខតំណែងអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២៥
២- លោក **ជួប គីមសាន**	មុខតំណែងអធិការ នៃអគ្គាធិការដ្ឋាន ចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០២៥។

មាត្រា ២ .- មន្ត្រីរាជការខាងលើ ត្រូវដាក់ពាក្យសុំចូលបម្រើការងារវិញរយៈពេល ០២ខែ មុនពេលកំណត់។ ក្នុងករណីសាមីខ្លួន មិនដាក់ពាក្យទេ ចាត់ទុកថាបោះបង់ការងារ នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌជាស្ថាពរ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៧ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា ១.- តាំងស៊ប់ទៅក្នុងឋាននន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខណ្ឌមន្ត្រីបច្ចេកទេសមធ្យម នៅរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដល់មន្ត្រីរាជការចំនួន ០៣ **រូប** ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដូចមានរាយនាមខាងក្រោម ៖

១-	លោក	**ខៀវ ពិសិដ្ឋ**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤
២-	លោក	**ឆា លីជីន**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤
៣-	លោកស្រី	**លី ហោងសុខរី**	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ៤

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .-

បន្ថយឋានន្តរស័ក្តិចំនួន ១ថ្នាក់ ពីលោកវរសេនីយ៍ឯក វ៉ាន់ វាសនា អត្តលេខ ៧៣៣៦៧ នាយនគរបាលជាន់ខ្ពស់ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ឱ្យមកនៅត្រឹមថ្នាក់ វរសេនីយ៍ទោ។

មាត្រា២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសមាជិកក្រុមប្រឹក្សាខេត្តកែប និងមន្ត្រីរាជការនៃរដ្ឋបាលខេត្តកែប ចំនួន២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោមៈ

១-ឯកឧត្តម	អ៊ុក សាខន	សមាជិកក្រុមប្រឹក្សាខេត្តកែប
២-លោកស្រី	អ៊ុល ភីរុណ	អភិបាលរង នៃគណៈអភិបាលខេត្តកែប

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុងរុនតាឯកតេជោសែន នៃខេត្តសៀមរាប
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការកំណត់ចំនួនគណៈអភិបាលក្រុងរុនតាឯកតេជោសែន នៃខេត្តសៀមរាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .—

តែងតាំងលោក **អ៊ុំ សុភ័ណ្ឌ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលក្រុងរុនតាឯកតេជោសែន ខេត្តសៀមរាប។

មាត្រា២ .—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៧រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើនិយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ ._

និយ័តកម្មតម្លើងក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម៖

១. លោក **ហៀវ ស៊ីថាត** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៥ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ

២. លោក **ម៉ក់ រឿត** ពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាល ថ្នាក់លេខ៥ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្រសួងមហាផ្ទៃ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

មាត្រា២ .—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃព្រហ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ ._

ផ្ទេរភារកិច្ចលោក **ឡូច់ សុមិន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ពីអភិបាល នៃគណៈអភិបាលស្រុកឆែប ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តព្រះវិហារ។

មាត្រា២ ._

៦- គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ត្រូវជ្រើសរើសទីតាំងសមស្រប និងតាមដងវិថីសំខាន់ៗ ដើម្បីចងបដាពាក្យស្លោកអបអរខួបលើកទី៧៥ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤នេះ តាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី៧៥ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី២៣ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២៤

ឞ

- មានសន្តិភាព មានការគាំពារ និងការអភិវឌ្ឍដល់កុមារ
- ពួតដៃគ្នានៃកម្លាំងសៅសង្គមក្នុងវិស័យកិច្ចការពារកុមារ គឺជាការលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍កុមារ
- សន្តិភាពបាននាំឱ្យមានការអភិវឌ្ឍធនធានមនុស្សក្នុងយុគសម័យឌីជីថល
- សន្តិភាពបានផ្តល់ស្នាមញញឹមដល់កុមារដែលជាអ្នកបន្តវេនក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ
- យុត្តិធម៌សង្គមសម្រាប់គ្រប់គ្នាដើម្បីបញ្ចប់ពលកម្មកុមារក្រោមម្លប់សន្តិភាព
- កុមារគ្រប់រូបត្រូវទទួលបានយុត្តិធម៌សង្គមដូចគ្នា
- កិច្ចគាំពារសង្គមសម្រាប់កុមារគ្រប់រូបដើម្បីលុបបំបាត់ពលកម្មកុមារ
- រួមគ្នាការពារកុមារមិនឱ្យធ្លាក់ចូលទៅក្នុងការកេងប្រវ័ញ្ចនិងការរំលោភបំពានគ្រប់ទម្រង់ ជាពិសេសតាមប្រព័ន្ធអនឡាញ
- បង្កើនការវិនិយោគលើកុមារថ្ងៃនេះគឺជាធនធានដ៏មានសក្តានុពលនាពេលអនាគត
- ចូលរួមលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិតគឺជាការលើកកម្ពស់កិច្ចការពារកុមារ
- រួមគ្នាការពារកុមារដើម្បីអភិវឌ្ឍគ្រួសារនិងសង្គមជាតិ
- រួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ
- កុមារជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ
- កុមារបើល្អ កូនល្អ សិស្សល្អ មិត្តល្អ ជាអនាគតពលរដ្ឋល្អ
- រួមគ្នាលើកកម្ពស់ការងារសមរម្យសម្រាប់កម្មករនិយោជិតវ័យក្មេង ក្នុងយុគសម័យសេដ្ឋកិច្ច និងសង្គមឌីជីថល
- គ្មានការប្រើប្រាស់ពលកម្មកុមារដើម្បីជំរុញយុទ្ធនាការ «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ»
- អបអរសាទរខួបលើកទី២៥នៃការអនុម័តអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- ប្តេជ្ញារួមគ្នាលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣ សរណន

សារាចរណែនាំ
ស្តីពី
ការចូលរួមកាន់ទុក្ខព្រះបរមសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានយាងចូលព្រះទិវង្គតនៅវត្តឧណ្ណាលោម កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១៧:៤០នាទី ដោយព្រះជរាពាធ ក្នុងព្រះជន្ម៩៣ព្រះវស្សា។ នៅក្នុងសេចក្តីទុក្ខដ៏ក្រៀមក្រំបំផុតនេះ រាជរដ្ឋាភិបាលបានប្រកាសយកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ជាថ្ងៃកាន់ទុក្ខផ្លូវការ ព្រមទាំងបាននិងកំពុងរៀបចំព្រះរាជពិធីបុណ្យថ្វាយព្រះបរមសព ប្រព្រឹត្តទៅប្រកបដោយភាពអធិកអធមនិងជាទីសក្ការៈ ស្របតាមប្រពៃណីជាតិ សក្តិសមនឹងព្រះកិត្តិនាមនិងព្រះកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចព្រះមហាសង្ឃរាជ។ ដើម្បីរៀបចំព្រះរាជពិធីដង្ហែនិងថ្វាយព្រះភ្លើងព្រះបរមសព ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ ឱ្យសក្តិសមនឹងព្រះគុណូបការៈដ៏ធំធេងរបស់សម្តេច ដែលបានបូជាថ្វាយចំពោះជាតិ សាសនា ព្រះមហាក្សត្រ ជាពិសេសម្តេចបានខិតខំអស់ពីព្រះកាយពលក្នុងការដឹកនាំព្រះសង្ឃ ការទ្រទ្រង់ពុទ្ធប្បញ្ញត្តិ និងលើកកម្ពស់ព្រះពុទ្ធសាសនានៅកម្ពុជា ឱ្យបានឧត្តុង្គឧត្តមឡើងវិញអស់មួយព្រះជន្មព្រះអង្គ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ៖

១- ប្រកាសថ្ងៃកាន់ទុក្ខជាផ្លូវការ លើកទី២ រយៈពេល១(មួយ)ថ្ងៃ គឺថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤។

២- គ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរបស់រដ្ឋនិងឯកជនទាំងអស់ គ្រប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងប្រជាជនទូទាំងប្រទេស ត្រូវបង្ហូតទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ មួយភាគបីនៃដងពីលើចុះមកក្រោម។

៣- គ្រប់ស្ថានីយវិទ្យុ និងទូរទស្សន៍ជាតិនិងឯកជនទាំងអស់ ត្រូវផ្អាកការសម្តែងនិងចាក់ផ្សាយនូវទស្សនីយភាពផ្សេងៗដែលមានលក្ខណៈសប្បាយគគ្រឹកគគ្រេង នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងជនរួមជាតិទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាកិច្ចចូលរួមព្រះបរមមរណទុក្ខដ៏ក្រៀមក្រំរកទីបំផុតគ្មាននេះ។

ថ្ងៃ អង្គារ ១៤ រោច ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០២៤

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

លេខ: ០២...រកព.ប្រក...

ប្រកាស

ស្តីពី

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាន របស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៣/០១៨ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១ .-

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានារបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន(រ.ក.ព.) ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ជំពូកទី២

រចនាសម្ព័ន្ធនាយកដ្ឋានរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

ប្រការ២ .-

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមាននាយកដ្ឋានចំណុះ ដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាលនិងពិធីការមានការិយាល័យចំណុះចំនួន៣(បី) រួមមាន៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យសរុប ផែនការ និងស្ថិតិ
- ការិយាល័យពិធីការនិងទំនាក់ទំនងសាធារណៈ។

២- នាយកដ្ឋានហិរញ្ញវត្ថុមានការិយាល័យចំណុះចំនួន៤(បួន) រួមមាន៖

- ការិយាល័យហិរញ្ញកិច្ច
- ការិយាល័យផែនការថវិកា
- ការិយាល័យផ្គត់ផ្គង់ ថែទាំនិងជួសជុល
- ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

៣- នាយកដ្ឋានធនធានមនុស្សមានការិយាល័យចំណុះចំនួន៣(បី) រួមមាន៖

- ការិយាល័យបុគ្គលិក
- ការិយាល័យបៀវត្ស
- ការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាព។

៤- នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មមានការិយាល័យចំណុះចំនួន៤(បួន) រួមមាន៖

- ការិយាល័យទំនាក់ទំនងអន្តរជាតិ
- ការិយាល័យស្រាវជ្រាវ នីតិកម្ម កិច្ចការច្បាប់ និងសន្ធិសញ្ញា
- ការិយាល័យភាសាបរទេស
- ការិយាល័យសាធារណមតិនិងផ្សព្វផ្សាយ។

៥- នាយកដ្ឋានព័ត៌មានវិទ្យាមានការិយាល័យចំណុះចំនួន៣(បី) រួមមាន៖

- ការិយាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- ការិយាល័យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន
- ការិយាល័យបណ្តុះបណ្តាលព័ត៌មានវិទ្យានិងបរិវត្តកម្មឌីជីថល។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ៣ .-

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានការិយាល័យ១(មួយ)រូប និងមានអនុប្រធានការិយាល័យមួយចំនួន តាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ផ្នែកទី១
ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានរដ្ឋបាលនិងពិធីការ

ប្រការ៤ .-

ការិយាល័យរដ្ឋបាលមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យរដ្ឋបាល
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ដឹកនាំសម្របសម្រួលសកម្មភាពការងាររដ្ឋបាលរបស់ រ.ក.ព.
- ចុះលេខចេញលើលិខិតបទដ្ឋានគតិយុត្តនិងឯកសារផ្សេងៗរបស់ រ.ក.ព.
- រៀបចំ ចាត់ថែង គ្រប់គ្រងរាល់លិខិតស្នាមនិងឯកសារចេញ-ចូល និងបញ្ជូនឯកសារផ្សេងៗរបស់ រ.ក.ព. តាមគ្រប់មធ្យោបាយ ទៅតាមបណ្តាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ធ្វើលិខិតឧទ្ទេសនាម ទិដ្ឋាការ ដីកាបញ្ជូន និងលិខិតបេសកកម្មជូនថ្នាក់ដឹកនាំនិងមន្ត្រី
- គ្រប់គ្រងនិងថែរក្សាត្រាឈ្មោះរបស់ថ្នាក់ដឹកនាំ រ.ក.ព. និងត្រារបស់ រ.ក.ព.
- រៀបចំកម្មវិធី លិខិតអញ្ជើញ និងសាលប្រជុំ សម្រាប់កិច្ចប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា ពិធីបុណ្យជាតិផ្សេងៗ និងកិច្ចប្រជុំផ្សេងៗទៀតរបស់ រ.ក.ព.
- ទទួលសំណូមពរឬអនុសាសន៍ពីក្រសួង ស្ថាប័ន អង្គភាពទទួលលិខិត ដើម្បីធ្វើការកែសម្រួល
- សម្របសម្រួលកិច្ចការទូទៅ និងផ្តល់ព័ត៌មានជូនសាធារណជន ដែលមកធ្វើទំនាក់ទំនងការងារជាមួយ រ.ក.ព.
- ធ្វើកំណត់ហេតុ ឬរបាយការណ៍កិច្ចប្រជុំរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានរដ្ឋបាលនិងពិធីការ
- ធ្វើប័ណ្ណចេញចូលយានយន្តក្នុងបរិវេណរបស់ រ.ក.ព.
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានរដ្ឋបាលនិងពិធីការប្រគល់ជូន។

ប្រការ៥ .-

ការិយាល័យសរុប ផែនការនិងស្ថិតិ មានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យសរុប ផែនការនិងស្ថិតិ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការសកម្មភាពទាក់ទងនឹងកិច្ចប្រជុំ សន្និបាត សន្និសីទ សិក្ខាសាលា និងពិធីបុណ្យជាតិផ្សេងៗរបស់ រ.ក.ព. ដោយពិគ្រោះយោបល់ជាមួយអង្គភាពចំណុះពាក់ព័ន្ធ

- សម្របសម្រួល ប្រមូលរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាននិងអង្គភាពចំណុះរបស់ រ.ក.ព.
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារនិងលើកទិសដៅបន្តរបស់ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានរដ្ឋបាលនិងពិធីការ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានរដ្ឋបាលនិងពិធីការប្រគល់ជូន។

ប្រការ៦ .-

ការិយាល័យពិធីការនិងទំនាក់ទំនងសាធារណៈមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យពិធីការនិងទំនាក់ទំនងសាធារណៈ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញរបស់ រ.ក.ព. ក្នុងការចុះបំពេញបេសកកម្មការងារលើទីតាំងជាក់ស្តែង
- រៀបចំនិងធ្វើបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិចូលរួមក្នុងសន្និបាត សន្និសីទ សិក្ខាសាលា ពិធីបុណ្យជាតិ កិច្ចប្រជុំ និងពិធីផ្សេងៗទៀតរបស់ រ.ក.ព.
- ចាត់ចែងអញ្ជើញភ្ញៀវជាតិនិងអន្តរជាតិចូលរួមក្នុងសន្និបាត សន្និសីទ សិក្ខាសាលា ពិធីបុណ្យជាតិ កិច្ចប្រជុំ និងពិធីផ្សេងៗទៀតរបស់ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានរដ្ឋបាលនិងពិធីការ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានរដ្ឋបាលនិងពិធីការប្រគល់ជូន។

ផ្នែកទី២
ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានហិរញ្ញវត្ថុ

ប្រការ៧ .-

ការិយាល័យហិរញ្ញកិច្ចមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យហិរញ្ញកិច្ច
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- គ្រប់គ្រងនិងតាមដានរាល់ចំណូលនិងចំណាយរបស់ រ.ក.ព.
- គាំទ្រ ត្រួតពិនិត្យ និងសម្របសម្រួលជាមួយអង្គភាពថវិកាក្នុងការគ្រប់គ្រងចំណូលនិងចំណាយរបស់អង្គភាពថវិកា
- សហការជាមួយអង្គភាពលទ្ធកម្មក្នុងការរៀបចំនិងអនុវត្តផែនការលទ្ធកម្មសាធារណៈរបស់ រ.ក.ព.
- រៀបចំឯកសារសុំធានាចំណាយ បុរេប្រទាន និងទូទាត់ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- រៀបចំនិងផ្ទេរប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភនានាជូនថ្នាក់ដឹកនាំនិងមន្ត្រី នៃ រ.ក.ព.
- រៀបចំ ចាត់ចែង និងដឹកនាំការចុះបញ្ជិកាគណនេយ្យដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ចូលរួមសហការក្នុងការរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសនិងប្រចាំឆ្នាំរបស់ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុប្រគល់ជូន។

ប្រការ៨ .-

ការិយាល័យផែនការថវិកាមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យផែនការថវិកា
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- សម្របសម្រួល ប្រមូលផ្តុំ បូកសរុប និងរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ រ.ក.ព.
- សហការជាមួយអង្គភាពលទ្ធកម្មក្នុងការរៀបចំផែនការលទ្ធកម្មសាធារណៈរបស់ រ.ក.ព.
- រៀបចំធ្វើនិយ័តកម្មថវិកា និងស្នើសុំឥណទានបន្ថែម ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងករណីចាំបាច់
- គ្រប់គ្រង តាមដាន និងវាយតម្លៃចលនាឥណទានថវិកានិងសាច់ប្រាក់របស់ដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគី
- រៀបចំ និងវិភាជចំណាយថវិកាប្រចាំឆ្នាំរបស់ រ.ក.ព.
- រៀបចំវិធីសាស្ត្រ ឧបករណ៍ និងយន្តការតាមដាន វាយតម្លៃការអនុវត្តថវិការបស់ រ.ក.ព.
- រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំនិងប្រចាំឆ្នាំរបស់ រ.ក.ព.
- សម្របសម្រួល ប្រមូលផ្តុំ បូកសរុប និងរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសនិងប្រចាំឆ្នាំរបស់ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុប្រគល់ជូន។

ប្រការ៩ .-

ការិយាល័យផ្គត់ផ្គង់ ថែទាំ និងជួសជុលមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យផ្គត់ផ្គង់ ថែទាំ និងជួសជុល

- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការតម្រូវការនិងការថែទាំចលនទ្រព្យ អចលនទ្រព្យ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ របស់ រ.ក.ព.
- លើកសំណើក្នុងការចំណាយលើការទិញ ថែទាំនិងជួសជុលចលនទ្រព្យនិងអចលនទ្រព្យ របស់ រ.ក.ព.
- លើកសំណើបែងចែកយានយន្ត សម្ភារៈបរិក្ខារ គ្រឿងបន្លាស់ សង្ហារិម ប្រេងឥន្ធនៈ និងសម្ភារៈផ្សេងៗ ជូនថ្នាក់ដឹកនាំនិងអង្គភាពចំណុះ រ.ក.ព.
- សហការជាមួយអង្គភាពលទ្ធកម្មក្នុងការរៀបចំនិងអនុវត្តផែនការលទ្ធកម្មសាធារណៈរបស់ រ.ក.ព.
- ត្រួតពិនិត្យ ថែទាំ និងជួសជុលចលនទ្រព្យ អចលនទ្រព្យ និងប្រព័ន្ធទឹក ភ្លើង លូ និងបណ្តាញផ្សេងៗ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុប្រគល់ជូន។

ប្រការ១០ .-

ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំនិងផ្សព្វផ្សាយរាល់សារាចរណែនាំ ប្រកាស អនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់អង្គភាពចំណុះ រ.ក.ព.
- រៀបចំធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល និងកើន ថយ
- រៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ រ.ក.ព. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំធ្វើស្លាកលេខ និងឯកសារបង់ពន្ធយានយន្តគ្រប់ប្រភេទរបស់ រ.ក.ព. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កត់ត្រាចូលក្នុងបញ្ជីសារពើភណ្ឌនូវទ្រព្យសម្បត្តិរដ្ឋ ចលនទ្រព្យនិងអចលទ្រព្យដែលទិញដោយថវិការដ្ឋ ឬជាអំណោយពីអង្គការជាតិ អន្តរជាតិ និងសប្បុរសជននានា
- រៀបចំនិងជម្រះបញ្ជីសារពើភណ្ឌនូវទ្រព្យរដ្ឋដែលអស់តម្លៃប្រើប្រាស់
- សហការ និងសម្របសម្រួលការងារថែទាំនិងជួសជុលទ្រព្យសម្បត្តិរដ្ឋរបស់ រ.ក.ព.
- ត្រៀមលក្ខណៈជាប្រចាំ ដើម្បីបង្ការនិងទប់ស្កាត់មហន្តរាយផ្សេងៗដែលអាចកើតមានជាយថាហេតុលើទ្រព្យសម្បត្តិរដ្ឋ
- រៀបចំសន្និធិឃ្លាំងប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ រ.ក.ព.

- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានហិរញ្ញវត្ថុ
- រៀបចំបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុប្រគល់ជូន។

ផ្នែកទី៣

ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានធនធានមនុស្ស

ប្រការ១១ .-

ការិយាល័យបុគ្គលិកមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យបុគ្គលិក
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការនិងលើកសំណើជ្រើសរើសមន្ត្រីរាជការ ភ្នាក់ងារជាតិនិងអន្តរជាតិជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យា
- គ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ ទីប្រឹក្សា ជំនួយការ ភ្នាក់ងារជាតិនិងអន្តរជាតិជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យាដោយទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមសហការរៀបចំការប្រឡងជ្រើសរើសមន្ត្រីរាជការដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រៀបចំបែងចែកមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់ រ.ក.ព.
- ទទួលបន្ទុកលើការងាររៀបចំលិខិតបញ្ជាក់វិញ្ញាបនបត្ររដ្ឋបាល
- រៀបចំឯកសារវាយតម្លៃស្នើសុំគ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំនិងមន្ត្រី ដោយសហការជាមួយអគ្គនាយកដ្ឋាននិងអង្គភាពចំណុះ រ.ក.ព.
- រៀបចំបណ្ណសម្គាល់ខ្លួនជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ទីប្រឹក្សា ជំនួយការ ភ្នាក់ងារជាតិនិងអន្តរជាតិជាប់កិច្ចសន្យា និងមន្ត្រីជាប់កិច្ចសន្យារបស់ រ.ក.ព.
- គ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាដែលមកបំពេញការងារនៅ រ.ក.ព.
- តាមដាននិងត្រួតពិនិត្យលើការអនុវត្តវិធានផ្ទៃក្នុងនិងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់ រ.ក.ព.
- រៀបចំយន្តការធានារ៉ាប់រងសង្គម និងយន្តការសង្គហធម៌ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ត្រីរាជការចូលនិវត្តន៍ ទីប្រឹក្សា ជំនួយការ និងមន្ត្រីជាប់កិច្ចសន្យារបស់ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានធនធានមនុស្ស

- រៀបចំរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានធនធានមនុស្សប្រគល់ជូន។

ប្រការ១២ .-

ការិយាល័យបៀវត្សមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យបៀវត្ស
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំបៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ ទីប្រឹក្សា ជំនួយការ និងមន្ត្រីជាប់កិច្ចសន្យារបស់ រ.ក.ព.
- រៀបចំដំឡើងថ្នាក់និងឋានន្តរសក្តជូនមន្ត្រីរាជការរបស់ រ.ក.ព.
- រៀបចំប្រាក់វិភាជន៍គ្រួសារសម្រាប់មន្ត្រីរាជការរបស់ រ.ក.ព.
- រៀបចំបែបបទតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនកម្មសិក្សាការីដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ
- រៀបចំដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សនិងក្រៅក្របខ័ណ្ឌដើម
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានធនធានមនុស្ស
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានធនធានមនុស្សប្រគល់ជូន។

ប្រការ១៣ .-

ការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាពមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍សមត្ថភាព
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំគោលនយោបាយ ផែនការអភិវឌ្ឍន៍ គ្រប់គ្រង និងបណ្តុះបណ្តាលមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា
- រៀបចំសេចក្តីជូនដំណឹងនិងផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍និងវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស ឱ្យបានទូលំទូលាយដល់មន្ត្រីរាជការរបស់ រ.ក.ព.
- សម្របសម្រួលនិងបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសរយៈពេលខ្លី មធ្យម និងវែង រួមមានសិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គសិក្សាជំនាញ ទស្សនកិច្ចសិក្សានិងការអភិវឌ្ឍសមត្ថភាពជាដើម
- វាយតម្លៃតម្រូវការបណ្តុះបណ្តាលមន្ត្រីរាជការរបស់ រ.ក.ព. ដោយសហការជាមួយនឹងអគ្គនាយកដ្ឋាននិងអង្គភាពចំណុះ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានធនធានមនុស្ស
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ

- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានធនធានមនុស្សប្រគល់ជូន។

ផ្នែកទី៤
ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម

ប្រការ១៤ .-

ការិយាល័យទំនាក់ទំនងអន្តរជាតិមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យទំនាក់ទំនងអន្តរជាតិ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ទំនាក់ទំនងជាមួយស្ថានទូតឬកុងស៊ុលបរទេសដែលមានទីស្នាក់ការនៅព្រះរាជាណាចក្រកម្ពុជា ក្រសួង និងស្ថាប័នពាក់ព័ន្ធលើកិច្ចការអន្តរជាតិ
- រៀបចំនិងអនុវត្តផែនការការងារកិច្ចសហប្រតិបត្តិការអន្តរជាតិនានារបស់ រ.ក.ព.
- ចូលរួមក្នុងដំណើរការនានានៃការចរចានិងការងារពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- ចូលរួមរៀបចំកំណត់ទូត សន្និសីទសារព័ត៌មាន សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ និងទំនាក់ទំនងសាធារណៈដទៃទៀត
- រៀបចំនិងផ្តល់យោបល់លើឯកសារ ជាអាទិ៍កំណត់ហេតុ លិខិតថ្លែងបំណង អនុស្សរណៈនៃការយោគយល់ ពិធីសារ កិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យកិច្ចការព្រំដែន
- ទទួលបន្ទុកទំនាក់ទំនងជាមួយស្ថាប័នស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ
- សហការជាមួយក្រសួង ស្ថាប័នជាតិពាក់ព័ន្ធ ក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចនានាដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែន ស្របតាមច្បាប់ជាតិនិងអន្តរជាតិ តាមមធ្យោបាយការទូត
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មប្រគល់ជូន។

ប្រការ១៥ .-

ការិយាល័យស្រាវជ្រាវ នីតិកម្ម កិច្ចការច្បាប់ និងសន្ធិសញ្ញាមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យស្រាវជ្រាវ នីតិកម្ម កិច្ចការច្បាប់ និងសន្ធិសញ្ញា
- រៀបចំសេចក្តីព្រាង ផ្តល់យោបល់ និងចងក្រងនូវសន្ធិសញ្ញានិងលិខិតូបករណ៍អន្តរជាតិនានាដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- សិក្សា វាយតម្លៃផលប៉ះពាល់នៃការផ្តួចផ្តើមរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ រ.ក.ព.
- រៀបចំផែនការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការព្រំដែនរបស់ រ.ក.ព.
- រៀបចំតាក់តែងនិងការផ្តល់យោបល់លើការកែសម្រួល ឬការធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានារបស់ រ.ក.ព.

- សិក្សាស្រាវជ្រាវច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទស្រាវជ្រាវជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចការព្រំដែនដោយសហការជាមួយវិទ្យាស្ថានជាតិកិច្ចការព្រំដែន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធកិច្ចការព្រំដែន
- ចូលរួមក្នុងកិច្ចប្រជុំការចរចាដោះស្រាយបញ្ហាព្រំដែនរបស់ រ.ក.ព. ជាមួយប្រទេសជិតខាង
- ចូលរួមផ្តល់យោបល់លើការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងស្ថាប័នពាក់ព័ន្ធ
- សិក្សានិងលើកយោបល់ពាក់ព័ន្ធនឹងការផ្តល់សច្ចាប័ន ឬទទួលយកសន្ធិសញ្ញាពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- ចូលរួមអនុវត្តសន្ធិសញ្ញាពាក់ព័ន្ធនឹងកិច្ចការព្រំដែនដែលកម្ពុជាជាភាគី
- សម្របសម្រួលរាល់កិច្ចការរៀបចំកិច្ចប្រជុំទ្វេឬពហុភាគី ពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- ចូលរួមក្នុងកិច្ចប្រជុំនិងការចរចាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង
- ចូលរួមនិងសហការជាមួយនឹងវិទ្យាស្ថានកិច្ចការព្រំដែន ដើម្បីបណ្តុះបណ្តាលនិងផ្សព្វផ្សាយកិច្ចព្រមព្រៀង សន្ធិសញ្ញា និងលិខិតូបករណ៍អន្តរជាតិនានាដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មប្រគល់ជូន។

ប្រការ១៦ .-

ការិយាល័យភាសាបរទេសមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យភាសាបរទេស
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការបកប្រែឯកសារ ដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែនរបស់ រ.ក.ព.
- រៀបចំស្រាវជ្រាវ ចងក្រងបញ្ជីបច្ចេកសព្ទ ពាក្យគន្លឹះ និងពាក្យច្បាប់នានាដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- ធ្វើទំនាក់ទំនងនិងសម្របសម្រួលជាមួយស្ថាប័នជាតិមានសមត្ថកិច្ចពាក់ព័ន្ធនឹងភាសាខ្មែរ
- ផ្តល់សេវាបកប្រែភាសា សម្រាប់កិច្ចប្រជុំ កិច្ចចរចាពាក់ព័ន្ធនឹងកិច្ចការព្រំដែនជាមួយប្រទេសជិតខាង និងកិច្ចប្រជុំផ្សេងៗ
- ផ្តល់សេវាបកប្រែភាសា សម្រាប់អង្គភាពចំណុះឱ្យ រ.ក.ព.
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មប្រគល់ជូន។

ប្រការ១៧ .-

ការិយាល័យសាធារណមតិនិងផ្សព្វផ្សាយមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យសាធារណមតិនិងផ្សព្វផ្សាយ
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីជំរុញប្រសិទ្ធភាពក្នុងការឆ្លើយតបព័ត៌មាននិងសាធារណមតិដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែន
- តាមដាន ចងក្រង និងឆ្លើយតបចំពោះមតិយោបល់ សំណួរនានា នៅលើប្រព័ន្ធបណ្ដាញទំនាក់ទំនងសង្គម ដោយសហការជាមួយការិយាល័យគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ
- សម្របសម្រួលជាមួយស្ថាប័នជាតិមានសមត្ថកិច្ចនិងបណ្ដាញផ្សព្វផ្សាយនានា លើការងារសម្របសម្រួលកិច្ចការព័ត៌មាន និងសាធារណមតិ និងផ្សព្វផ្សាយ
- ធ្វើកិច្ចការងារពង្រឹងសាធារណមតិ តាមរយៈការតាមដានក្ដាប់ស្ថានការណ៍ ឃោសនា ពន្យល់ និងការពាររូបភាពវិជ្ជមានរបស់ រ.ក.ព.
- រៀបចំការផ្សាយផ្ទាល់តាមប្រព័ន្ធបណ្ដាញសង្គមនូវព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងកិច្ចការព្រំដែនជូនសាធារណជន ដោយសហការជាមួយនឹងនាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំផែនការផ្សព្វផ្សាយស្ដីពីសកម្មភាពរបស់ រ.ក.ព.
- គ្រប់គ្រងការផលិត រូបភាព វីដេអូ និងសម្របសម្រួលខ្លឹមសារ មាតិកាព័ត៌មាន និងឯកសារនានា ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធបណ្ដាញសង្គម ព្រមទាំងរក្សាទុកជាបណ្ណសារ
- ចូលរួមក្នុងការរៀបចំខិត្តប័ណ្ណផ្សព្វផ្សាយ និងសារលិខិតនានា សម្រាប់កម្មវិធីបុណ្យជាតិ អន្តរជាតិ និងកម្មវិធីផ្សេងៗ
- ចូលរួមរៀបចំសន្និសីទសារព័ត៌មាននានា ដោយសហការជាមួយការិយាល័យពិធីការ
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្មប្រគល់ជូន។

ផ្នែកទី៥
ភារកិច្ចការិយាល័យចំណុះនាយកដ្ឋានព័ត៌មានវិទ្យា

ប្រការ១៨ .-

ការិយាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេនិងផែនការសកម្មភាពការងារពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលឌីជីថល

- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំដែលពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យានិងឌីជីថល
- ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យព័ត៌មានវិទ្យានិងឌីជីថល
- បង្កើត គ្រប់គ្រង និងសម្របសម្រួលនូវការដំណើរការគេហទំព័រ ប្រព័ន្ធអ៊ីមែល និងរាល់ប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមនានារបស់ រ.ក.ព.
- សិក្សាវាយតម្លៃអំពីតម្រូវការនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលរបស់ រ.ក.ព. ដោយធ្វើការសហការជាមួយអគ្គនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពចំណុះនានា
- កសាង អភិវឌ្ឍ ថែទាំ ជួសជុល និងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឱ្យសមស្របតាមកម្រិតតម្រូវការនៃបច្ចេកវិទ្យាដែលបម្រើឱ្យ រ.ក.ព. ដោយសហការជាមួយអគ្គនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពពាក់ព័ន្ធចំណុះនានា
- រៀបចំតភ្ជាប់ និងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទ ឬកិច្ចប្រជុំរបស់រាជរដ្ឋាភិបាលនានា
- លើកសំណើក្នុងការចំណាយលើការថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលរបស់ រ.ក.ព.
- សម្របសម្រួលនិងសហការផ្តល់សេវាបច្ចេកវិទ្យាព័ត៌មានដល់អគ្គនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពចំណុះ រ.ក.ព.
- គ្រប់គ្រងនិងថែទាំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- ចូលរួមសិក្សាវាយតម្លៃលទ្ធកម្មសម្ភារៈបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានព័ត៌មានវិទ្យាប្រគល់ជូន។

ប្រការ១៩ .-

ការិយាល័យសន្តិសុខបច្ចេកវិទ្យាព័ត៌មានមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- សិក្សា និងរៀបចំនិយាម និងវិធានចាំបាច់នានា ដើម្បីរក្សាសន្តិសុខព័ត៌មានវិទ្យាសម្រាប់រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដោយធ្វើការសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចនានា
- សម្របសម្រួលបង្កើតប្រព័ន្ធជូនដំណឹងផ្ទៃក្នុងអំពីបញ្ហាសន្តិសុខព័ត៌មានវិទ្យារបស់ រ.ក.ព.
- រៀបចំការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីនិងថ្នាក់ដឹកនាំអំពីបញ្ហាសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ប្រមូលនិងរៀបចំចងក្រងទិន្នន័យ ឬឯកសារដែលពាក់ព័ន្ធនឹងបញ្ហាសន្តិសុខព័ត៌មានវិទ្យាដែលទទួលបានពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា
- ធ្វើការសិក្សាវាយតម្លៃជាប្រចាំលើប្រព័ន្ធសន្តិសុខនៃប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានរបស់ រ.ក.ព.

- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានព័ត៌មានវិទ្យាប្រគល់ជូន។

ប្រការ២០ .-

ការិយាល័យបណ្តុះបណ្តាលព័ត៌មានវិទ្យានិងបរិវត្តកម្មឌីជីថលមានភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យបណ្តុះបណ្តាលព័ត៌មានវិទ្យានិងបរិវត្តកម្មឌីជីថល
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់ការិយាល័យ
- រៀបចំផែនការនិងកម្មវិធីបណ្តុះបណ្តាលថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃអង្គភាពចំណុះ រ.ក.ព. លើវិស័យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលស្របតាមគោលនយោបាយឌីជីថលរបស់រាជរដ្ឋាភិបាល
- បណ្តុះបណ្តាល ពង្រឹង និងធ្វើបច្ចុប្បន្នកម្មសមត្ថភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា នៃអង្គភាពចំណុះ រ.ក.ព. ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថលប្រកបដោយសុវត្ថិភាព
- រៀបចំចងក្រងធ្វើទំនើបកម្មខ្លឹមសារឯកសារបណ្តុះបណ្តាលធនធានមនុស្សលើវិស័យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
- ស្រាវជ្រាវរៀបចំកម្មវិធីសិក្សា ការបង្ហាត់បង្រៀន គ្រូឧទ្ទេស ឧបករណ៍បច្ចេកទេសមធ្យោបាយនិងសិក្ខាកាមពាក់ព័ន្ធនឹងព័ត៌មានវិទ្យានិងឌីជីថល
- ចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់រយៈពេលខ្លីនិងរយៈពេលមធ្យមរបស់នាយកដ្ឋានព័ត៌មានវិទ្យា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាននាយកដ្ឋានព័ត៌មានវិទ្យាប្រគល់ជូន។

ជំពូកទី៣
អវសានប្បញ្ញត្តិ

ប្រការ២១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២២ .-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសកិច្ចការព្រំដែន អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងអភិវឌ្ឍន៍តំបន់ព្រំដែន ប្រធានវិទ្យាស្ថានជាតិកិច្ចការព្រំដែន ប្រធានមជ្ឈមណ្ឌលតម្កល់ឯកសារ ផែនទី និងទិន្នន័យព្រំដែន

គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពចំណុះរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២៤

រដ្ឋមន្ត្រី

ឡាំ ជា

កន្លែងទទួល ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០២ រកធ.ប្រកចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានារបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
អង្គការលេខនៃរចនាសម្ព័ន្ធរបស់ការិយាល័យចំណុះនាយកដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

- នាយកដ្ឋានរដ្ឋបាល និងពិធីការ
  - ការិយាល័យរដ្ឋបាល
  - ការិយាល័យសរុប ផែនការ និងស្ថិតិ
  - ការិយាល័យពិធីការនិង ទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានហិរញ្ញវត្ថុ
  - ការិយាល័យហិរញ្ញកិច្ច
  - ការិយាល័យផែនការថវិកា
  - ការិយាល័យផ្គត់ផ្គង់ ថែទាំ និងជួសជុល
  - ការិយាល័យគ្រប់គ្រង ទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានធនធានមនុស្ស
  - ការិយាល័យបុគ្គលិក
  - ការិយាល័យបៀវត្ស
  - ការិយាល័យបណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាព
- នាយកដ្ឋានទំនាក់ទំនង អន្តរជាតិនិងនីតិកម្ម
  - ការិយាល័យទំនាក់ទំនង អន្តរជាតិ
  - ការិយាល័យស្រាវជ្រាវ នីតិកម្ម កិច្ចការច្បាប់និងសន្ធិសញ្ញា
  - ការិយាល័យភាសាបរទេស
  - ការិយាល័យសាធារណមតិនិង ផ្សព្វផ្សាយ
- នាយកដ្ឋានព័ត៌មានវិទ្យា
  - ការិយាល័យហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាននិងឌីជីថល
  - ការិយាល័យសន្តិសុខ បច្ចេកវិទ្យាព័ត៌មាន
  - ការិយាល័យបណ្តុះបណ្តាល ព័ត៌មានវិទ្យានិងបរិវត្តកម្ម ឌីជីថល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១០៧ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៤

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ៦៦៩/២៤ គ.វ.ក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន ស៊ីន ហេង យី (ខេមបូឌា) អ៊ិនធើណេសិនណល ត្រេឌីង ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ីន ហេង យី (ខេមបូឌា) អ៊ិនធើណេសិនណល ត្រេឌីង ឯ.ក (XIN HENG YI (CAMBODIA) INTERNATIONAL TRADING CO., LTD.)** តំណាងដោយលោក **YAN LIXIN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ **EJ4327785** ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**ភូមិត្រពាំងឫស្សី ឃុំសូរគី ស្រុកបាទី ខេត្តតាកែវ**។

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកាត់ដេរសម្លៀកបំពាក់ ស៊ីន ហេង យី (ខេមបូឌា) អ៊ិនធើណេសិនណល ត្រេឌីង ឯ.ក** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តតាកែវ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ
-រដ្ឋបាលស្រុកបាទី
-រដ្ឋបាលឃុំស្វាគើ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី